

## ជំពូកទី ៦

# ការប្រាស្រ័យទាក់ទង

ការប្រាស្រ័យទាក់ទងកើតឡើងនៅពេល :-

- មនុស្សម្នាក់បានបញ្ជូនសារទៅ ហើយ
- មនុស្សម្នាក់ទៀតបានទទួលសារ និងឆ្លើយតបវិញ។

ទារកចាប់ផ្តើមប្រាស្រ័យទាក់ទងតាំងពីកើតមកភ្លាម គឺតាំងពីមុនពេលគេរៀននិយាយទៅទៀត។ មុនពេលកុមារអាចជជែកលេងពីនេះពីនោះជាមួយមនុស្សឯទៀត គេត្រូវការរៀនបំណិនប្រាស្រ័យទាក់ទងងាយៗជាច្រើន ដូចជា :-




① យល់ដឹងពាក្យ និងសំណើងាយៗ



② ចេះប្រើកាយវិការ




③ ចេះនិយាយពាក្យងាយៗ




④ ចេះប្រើប្រយោគខ្លីៗ

គ្រប់បំណិនប្រាស្រ័យទាក់ទងទាំងនេះ នឹងជួយកុមារឱ្យមានអារម្មណ៍ជិតស្និទ្ធនឹងក្រុមគ្រួសាររបស់គេ។ ទៅថ្ងៃមុខបំណិនទាំងនេះនឹងជួយគេឱ្យចេះលេងកំសាន្តជាមួយក្មេងៗដទៃទៀត។

## របៀបដែលបញ្ហាគំហើញប៉ះពាល់ដល់ការប្រាស្រ័យទាក់ទង

ទារកតូចអាចបញ្ជូនសារអំពីអ្វីដែលគេគិត ឬ អារម្មណ៍ ដោយការកម្រើករាងកាយដូចជា (ងាកក្បាល) ដោយការធ្វើសម្លេងដូចជា (យំ) និងដោយការផ្លាស់ប្តូរទឹកមុខដូចជា (ធ្វើមុខជូរ ឬ ជ្រួញចិញ្ចើម)។ សមាជិកគ្រួសារស្វែងយល់ពីអត្ថន័យនៃសាររបស់ទារក ហើយពួកគាត់ឆ្លើយតបវិញ។







**ទារកគ្រប់រូបចង់លេងកំសាន្ត។ តែទារកនេះត្រូវការជួយជ្រោមជ្រែងដើម្បីចាប់ផ្តើមចេះលេង។**

ទារកដែលមិនអាចមើលឃើញច្បាស់ ហាក់ដូចជាស្ងៀមស្ងាត់ណាស់។ គេអាចបញ្ជូនសារតែពីរ-បីប៉ុណ្ណោះ ពីព្រោះគេប្រហែលកំពុងព្យាយាមស្វែងយល់អំពីសម្លេងនៅជុំវិញខ្លួនគេ។ ក្រុមគ្រួសាររបស់ទារកអាចជួយទារកឱ្យចេះប្រាស្រ័យទាក់ទងដោយការបញ្ជូនសារតាមវិធីដែលទារកអាចយល់ និងដោយរៀនស្វែងយល់អំពីសារទាំងឡាយដែលទារកបានបញ្ជូន។

ឪពុកម្តាយត្រូវតែរៀនសម្គាល់ប្រភេទផ្សេងៗគ្នានៃសារដែលទារករបស់គាត់បានបញ្ជូន។ ឧទាហរណ៍ ទារកដែលមើលឃើញប្រើភ្នែកទាក់ទងដើម្បីបង្ហាញថា គេកំពុងតែការយកចិត្តទុកដាក់។ តែទារកពិការភ្នែកអាចលើកដៃ ឬ កំរើករាងកាយដើម្បីផ្ញើសារដូចគ្នានោះ។ ឬក៏គេអាចនៅស្ងៀមស្ងាត់ ធ្វើដូច្នេះគេអាចយកចិត្តទុកដាក់ស្តាប់នូវអ្វីដែលកំពុងកើតឡើងជុំវិញខ្លួនគេ។




ឪពុកម្តាយក៏ត្រូវតែផ្ញើប្រភេទសារខុសៗគ្នាត្រឡប់ទៅទារកវិញផងដែរ។ វាជារឿងដែលងាយនឹងភ្លេច ថាទារកមិនអាចមើលឃើញស្នាមញញឹម ឬ ការមើលរបស់ឪពុកម្តាយខ្លួនឡើយ ហើយពួកគាត់ត្រូវតែផ្ញើសារទៅទារកតាមរយៈការស្ទាប ឬ សម្លេង។

**បើសិនជាគាត់ចាក់ក្រឡេកកូន នោះកូនគាត់អាចញញឹមតបវិញ។**

## ការនិយាយរកកូនអ្នកគឺសំខាន់បំផុត

កុមារដែលមិនអាចមើលឃើញច្បាស់ មានការពិបាកច្រើនក្នុងការរៀនស្វែងយល់ពីអ្វីដែលជាអត្ថន័យរបស់ពាក្យជាងកុមារដទៃទៀត ។ នេះដោយសារតែជារឿយៗ គេមិនអាចមើលឃើញអ្វីដែលមនុស្សនិយាយសំដៅទៅរក ។ ក្នុងនោះផងដែរការរៀនចេះស្ដាប់សំដីមនុស្សម្នានិយាយគ្នា និងចេះនិយាយ គឺមានសារៈសំខាន់ខ្លាំងណាស់សំរាប់កុមារពិការភ្នែក ពីព្រោះបំណិនទាំងនេះជួយឱ្យគេយល់អ្វីៗទាំងឡាយដែលគេមើលមិនឃើញ ។




ខណៈពេលអ្នកធ្វើការងារប្រចាំថ្ងៃ ឬ លេងកំសាន្តជាមួយកូន ចូររក្សាការនិយាយរកកូនដោយប្រយោគខ្លីនិងងាយៗ ។ ដំបូងវាអាចលំបាកបន្តិចហើយ បើសិនជាអ្នកមិនមានទម្លាប់និយាយច្រើន ។ តែសូមចាំថា នេះគឺជាវិធីសំខាន់មួយក្នុងចំណោមវិធីទាំងឡាយដែលកូនអ្នករៀនអំពីព្រឹត្តិការណ៍ទាំងនេះ-ជាពិសេសអ្វីៗទាំងឡាយណាដែលនាងមិនធ្លាប់មានបទពិសោធន៍ដោយខ្លួនឯង ។ នៅពេលខាងមុខ ប្រការនេះនឹងជួយនាងកាន់តែច្រើន ដើម្បីនិយាយអំពីវាជាមួយមនុស្សដទៃ ។







ចូរចាំថាកុមារដែលមើលឃើញរៀនយ៉ាងច្រើនអំពីព្រឹត្តិការណ៍ទាំងឡាយដោយការសង្កេតមើល ។ កុមារដែលមិនអាចមើលឃើញច្បាស់ប្រើវិញ្ញាណឯទៀតដើម្បីរៀនអំពីព្រឹត្តិការណ៍ទាំងឡាយ ។ ពេលណាក៏ដោយឱ្យតែអាចធ្វើបាន ចូរឱ្យនាងស្ទាប, ភ្លក់រស, ជាតិ ឬ ហិតក្លិនរបស់អ្វីៗដែលអ្នកនិយាយអំពីវា ។ ប្រការនេះជួយឱ្យនាងយល់អត្ថន័យរបស់ពាក្យទាំងនោះ ។

# សកម្មភាព

សកម្មភាពខាងក្រោមបានចែកចេញជាពីរផ្នែក :-

- សកម្មភាពដែលប្រើមុនពេលទារករៀននិយាយ និង
- សកម្មភាពជាច្រើនទៀតប្រើនៅពេលទារកចាប់ផ្តើមចេះនិយាយ ។

បើកូនអ្នកអាចមើលឃើញបានតិចតួច អ្នកត្រូវប្រាកដថាបានយកសកម្មភាពទាំងនេះមកបញ្ច្រាប និងប្រើប្រាស់ដើម្បីធ្វើយ៉ាងណាឱ្យកូនចេះប្រើគំហើញដែលនៅសេសសល់បានល្អបំផុត ( សូមអានជំពូកទី 4 ) ។

## ការប្រាស្រ័យទាក់ទងមុនពេលកូនចេះនិយាយ

### ការផ្លាស់ប្តូរវេនគ្នា

ការផ្លាស់ប្តូរវេនគ្នាជាមួយកូនមានន័យថា ទីមួយ-អ្នកបញ្ជូនសារទៅឱ្យកូន ឬ ឆ្លើយតបទៅសារដែលកូនកំពុងផ្ញើមកឱ្យអ្នក និងទីពីរ-សាកល្បងធ្វើការឱ្យ-ទៅ-ឱ្យ-មករវាងអ្នកនិងកូន ។

រៀងរាល់ពេលអ្នកផ្លាស់ប្តូរវេនជាមួយកូន អ្វីមួយអាចកើតឡើងខុសៗគ្នា ។ តែក៏មានគោលការណ៍ណែនាំទូទៅមួយចំនួនដែលអាចជួយធ្វើឱ្យការប្តូរវេនគ្នាមានដំណើរការល្អ :-

1. ដើម្បីចាប់ផ្តើម ចូរឱ្យទារកបានដឹងថាអ្នកនៅក្បែរ ហើយត្រៀមជាស្រេចដើម្បីលេងកំសាន្តជាមួយនាង ។
2. ឱ្យវេនកូនធ្វើមុន ដូច្នេះកូនអាចឱ្យអ្នកដឹងពីតម្រុយថាគេចង់ធ្វើអ្វី ។ តែបើអ្នករង់ចាំយូរ អ្នកចាប់ផ្តើមខ្លួនឯងមុនកូន ។
3. នៅពេលកូនឆ្លើយតបទៅអ្នកវិញក្នុងវិធីណាក៏ដោយ ចូរចាត់ទុកថានោះជាវេនរបស់កូន ហើយឆ្លើយតបទៅវិញ ។ តាមវិធីនេះកូនដឹងថាអ្នកចំណាំបានសកម្មភាពរបស់គេ ហើយគេក៏មានការពេញចិត្ត ។ បើកូនមិនតបទៅអ្នកវិញ ចូរព្យាយាមជួយកូនឱ្យតបបាន "រហ័ស" ដូចជាប៉ះលើដៃកូនដើម្បីរំលឹកកូនថា វាជាវេនរបស់គេ ។ វាក៏អាចជួយផងដែរដោយប្រើសកម្មភាពដែលពាក់ព័ន្ធនឹងការឱ្យ-ទៅ-ឱ្យ-មក ដូចជាការរមៀលបាល់ទៅវិញទៅមករវាងអ្នកនិងកូន ។
4. នៅពេលដល់វេនអ្នក ចូរព្យាយាមប្រើពេលឱ្យស្មើគ្នានឹងពេលទារករបស់អ្នកបានចំណាយសំរាប់វេនរបស់គេ ។
5. ឱ្យទារករបស់អ្នកឈប់លេងដោយខ្លួនឯងនៅពេលណាគេចង់ឈប់ ។ ការលេងផ្លាស់វេនចំណាយពេលត្រឹមតែមួយ ឬ ពីរនាទីប៉ុណ្ណោះ ពីព្រោះទារកអាចផ្តោតការយកចិត្តទុកដាក់បានត្រឹមតែរយៈពេលខ្លីមួយប៉ុណ្ណោះ ។



## ➤ វិធីលើកទឹកចិត្តទារកឱ្យចេះផ្លាស់ប្តូរវេន

ការផ្លាស់ប្តូរវេនជួយឱ្យទារកដឹងថា គេអាចមានឥទ្ធិពលលើអ្វីដែលអ្នកឯទៀតបានធ្វើដោយការបញ្ជូនសារទៅឱ្យពួកគេ។ ប្រការនេះកាន់តែធ្វើឱ្យទារកចាប់អារម្មណ៍ចំពោះព្រឹត្តិការណ៍ទាំងឡាយ ហើយកាន់តែចង់ប្រាស្រ័យទាក់ទងថែមទៀត។ ការផ្លាស់ប្តូរវេនក៏ជួយឱ្យទារករៀនអំពីបំណិនប្រាស្រ័យទាក់ទងដែលសំខាន់ៗដូចជា កិច្ចចាប់ផ្តើម "ការសន្ទនា" របស់គេ, របៀបយកចិត្តទុកដាក់ និង របៀបឆ្លើយតបទៅនឹងសាររបស់ក្រុមគ្រួសារខ្លួន។




1. **ម៉ារី**ប្រាប់ក្មួយប្រុសគាត់ឱ្យដឹងថា គាត់នៅក្បែរ និងត្រៀមលេងជាស្រេច ដោយនិយាយយ៉ាងស្រទន់ជាមួយ**រ៉ុណេ** បន្ទាប់មកប៉ះដៃរបស់**រ៉ុណេ**ថ្នមៗ។




2. នៅពេល**រ៉ុណេ**ឆ្លើយនឹងការប៉ះរបស់គាត់ ដោយស្រវាលេងមុខរបស់គាត់ **ម៉ារី**បានតបទៅ**រ៉ុណេ**វិញ ដើម្បីឱ្យគេដឹងថាគេបានធ្វើទង្វើមួយសំខាន់។




3. **ម៉ារី**រង់ចាំឱ្យ**រ៉ុណេ**បញ្ចប់វេនរបស់គេ ហើយពេលនោះដល់វេនរបស់គាត់ គាត់ប៉ះច្រមុះ**រ៉ុណេ** ដោយម្រាមដៃគាត់។



4. បន្ទាប់មកគាត់រង់ចាំឱ្យ**រ៉ុណេ**ធ្វើតបទៅគាត់វិញ ហើយធ្វើសកម្មភាពផ្លាស់វេនគ្នាតទៅទៀត។

# ត្រៀមរៀបចំដើម្បីចេះនិយាយ

## ➤ វិធីជួយកូនឱ្យចេះបញ្ជូនសារដោយប្រើរាងកាយរបស់គេ ( កាយវិការ)

ចូរសាកល្បងលេងល្បែងដែលប្រើកាយវិការ ។




**កុមារនេះដឹងថា ការចង្អុលគឺជាការផ្ញើសារ។**

ចូរពន្យល់ន័យអំពីភាពខុសគ្នានៃសារជាកាយវិការ







## ➤ វិធីត្រៀមរៀបចំកូនឱ្យរៀននិយាយ

ចូរនិយាយអំពីការងារអ្វីក៏ដោយ ឬសកម្មភាពដែលអ្នកកំពុងធ្វើ និងរបៀបដែលអ្នកធ្វើវា ។



នេះជាឧទាហរណ៍មួយផ្សេងទៀត :-




បងប្រុសរបស់**ភក្តី**កំពុងប្រើពាក្យដើម្បីរៀបរាប់ល្បែងលេងមួយដែល**ភក្តី**ចូលចិត្តលេង។

ចូរនិយាយពីវត្ថុ និងអំពីអ្វីៗដែលអ្នកធ្វើប្រចាំថ្ងៃ។




បើអ្នកប្រើពាក្យសំរាប់ចំណែកនៃរាងកាយ និងវត្ថុសាមញ្ញម្តងហើយម្តងទៀតនៅក្នុងសកម្មភាពរៀងរាល់ថ្ងៃរបស់អ្នក កូនរបស់អ្នកនឹងរៀននូវអ្វីដែលជាន័យនៃពាក្យមុនពេលគេអាចនិយាយវា។

កុមារដែលពិបាកក្នុងការមើលឃើញ មិនអាចឃើញពីរបៀបដែលមនុស្សម្នាទាំងឡាយបង្ហាញពីអារម្មណ៍ដូចជាខ្លាច ឬ រីករាយ។ គេត្រូវការឱ្យជួយដើម្បីស្វែងយល់ថាអ្វីដែលជាអារម្មណ៍។ ចូរលើកទឹកចិត្តកូនឱ្យស្ទាបអង្អែលមុខរបស់អ្នក និងស្ទាបមុខរបស់គេ ដើម្បីឱ្យដឹងថាតើអារម្មណ៍បានបង្ហាញដោយរបៀបណានៅលើមុខមនុស្ស។




**ចូរនិយាយអំពីអារម្មណ៍ និងការរំជួលចិត្តដែលអ្នក ឬ កូនអ្នកធ្លាប់មានបទពិសោធន៍។**

## នៅពេលដែលកូនអ្នកចាប់ផ្ដើមនិយាយ

### ➤ វិធីជួយកូនឱ្យចេះប្រាស្រ័យទាក់ទងដោយពាក្យនិយាយ

កុមារតូចមិនទាន់ដឹងគ្រប់គ្រាន់នូវពាក្យនិយាយដើម្បីនិយាយរឿងទាំងឡាយដែលគេចង់និយាយនោះទេ។ ដូច្នេះ ជារឿយៗគេនឹងប្រើសម្លេង ឬ សំដីដែលមិនមានន័យ-ពាក្យមួយចំនួន-ដើម្បីនិយាយអ្វីៗជាច្រើនទៀត។ កុំប្រាប់កូនថា គេបាននិយាយអ្វីមួយខុសឱ្យសោះ។ ចូរជួយឱ្យភាសារបស់កូនលូតលាស់ដោយការបំពេញពាក្យដែលកូនមិនបាននិយាយជំនួសវិញ។







ចូររង់ចាំឱ្យកូនសួររកអ្វីមួយ ជាជាងឱ្យវាទៅកូន មុនកូនសុំវា។









ចូរសួរសំណួរដែលតម្រូវឱ្យកូនឆ្លើយឱ្យច្រើនជាងពាក្យ "បាទ" ឬ "ចាស"។




ឱ្យកូននាំមុខក្នុងការនិយាយ ខណៈពេលដែលអ្នកកំពុងស្តាប់។ ចូរនិយាយពីអ្វីដែលកូនចង់និយាយ។

ចូរប្រាប់កូនឱ្យដឹង នៅពេលដែលសាររបស់កូនមិនច្បាស់។ ជួនកាល ទោះជាអ្នកព្យាយាមខ្លាំងយ៉ាងណាក្តី អ្នកនៅតែមិនយល់ពីអ្វីដែលកូនកំពុងព្យាយាមនិយាយប្រាប់។ អ្នកអាចព្យាយាមសួរកូនថា :-




បើអ្នកនៅតែមិនយល់ពីអ្វីដែលកូនកំពុងព្យាយាមនិយាយប្រាប់ ចូរប្រាប់កូនឱ្យដឹង។



## បញ្ហាសាមញ្ញៗនៅពេលកំពុងរៀននិយាយ

កុមារដែលអាចមើលឃើញយល់នូវគំនិតសំរាប់ប្រាស្រ័យទាក់ទងដោយការមើលមនុស្សម្នានិយាយគ្នា ។ តែកុមារដែលមិនអាចមើលឃើញច្បាស់បាត់បង់ឱកាសនេះ ( មិនយល់ពីបញ្ហានេះ) ហើយចេះនិយាយក្រោយកុមារដែលអាចមើលឃើញ ។ ដូច្នេះនៅពេលកំពុងរៀននិយាយ កុមារដែលមិនអាចមើលឃើញ ហើយជាញឹកញាប់គេ :-

- និយាយត្រាប់តាមសំដីមនុស្សម្នាបាននិយាយ ជាជាងនិយាយពីគំនិតរបស់ខ្លួនឯង ។
- ប្រើពាក្យដូចជា "គេ-គាត់" "នាង" "វា" និង"អ្នក" ( សព្វនាម) មិនត្រូវ ។
- មិនបែរសំដៅទៅរកបុគ្គលដែលកំពុងនិយាយ ។
- សួរសំណួរជាច្រើន ។

បើកូនអ្នកមានបញ្ហាមួយចំនួនក្នុងចំណោមបញ្ហាទាំងនេះ នេះជាសកម្មភាពខ្លះៗដែលប្រហែលអាចជួយបាន ។

### ➤ វិធីជួយកូនឱ្យចេះនិយាយពីគំនិតរបស់ខ្លួន

ជារឿងធម្មតាចំពោះកុមារតូចក្នុងការនិយាយត្រាប់តាមសំដីមនុស្សម្នានិយាយ ។ ជាការពិត កុមារតូចគួរត្រូវបានលើកទឹកចិត្តក្នុងការនិយាយត្រាប់តាមសំដីមនុស្សពីព្រោះប្រការនេះជួយកុមារឱ្យរៀននិយាយ ។ ប៉ុន្តែកុមារដែលមិនអាចមើលឃើញច្បាស់ ជារឿយៗបន្តនិយាយត្រាប់តាមសំដីមនុស្សអស់ពេលយ៉ាងយូរ ( រាប់ថ្ងៃ ឬ អាទិត្យ) ជាជាងនិយាយពីការគិតរបស់ខ្លួន ។ រឿងនេះកើតឡើងដោយសារ :-

- កូនអ្នកប្រហែលចង់បន្តនិយាយលេងជាមួយអ្នក តែមិនចេះពាក្យគ្រប់គ្រាន់ដើម្បីប្រាប់អ្នកពីគំនិតនេះ ។
- កូនប្រហែលជាមិនយល់ពាក្យសំដីរបស់អ្នក ដោយសារគេមិនអាចមើលឃើញពីអ្វីដែលអ្នកកំពុងនិយាយ ។
- កូនអាចនិយាយត្រាប់តាមសំដី ដើម្បីព្យាយាមយល់អត្ថន័យនៃពាក្យទាំងនោះ ។

បើសិនជាកូនអ្នកនិយាយត្រាប់តាមអ្វីដែលអ្នកបាននិយាយ ឱ្យកូនដឹងថាអ្នកបានឮគេនិយាយ បន្ទាប់មកពង្រីកប្រយោគដែលកូនបាននិយាយ ។ ប្រការនេះបង្ហាញឱ្យកូនដឹងថាអ្នកកំពុងស្តាប់គេ ។ វាក៏បង្ហាញឱ្យកូនដឹងផងដែរថាមានវិធីផ្សេងទៀត ដើម្បីឆ្លើយតបមកវិញ ។






នៅពេលកូននិយាយត្រាប់តាមសំដីរបស់អ្នក ចូរព្យាយាមយល់ពីអ្វីដែលកូនកំពុងព្យាយាមនិយាយប្រាប់ ។ ជារឿយៗវាជួយដល់អ្នកក្នុងការរកមើលពីគំនិត និងអារម្មណ៍ដែលកូនប្រហែលចង់និយាយ តែមិនដឹងថាត្រូវនិយាយបែបណា ។




ចូរផ្តល់ឱកាសឱ្យច្រើនដល់កូននៅក្នុងសហគមន៍ ដើម្បីរៀនអំពីព្រឹត្តិការណ៍ទាំងឡាយ និងស្ដាប់អ្វីៗដែលអ្នកនិយាយអំពីពួកវា ។ ប្រការនេះនឹងជួយកូនឱ្យរៀនពាក្យបានកាន់តែច្រើន ធ្វើដូចនេះកូននឹងមិនសូវនិយាយត្រាប់តាមសំដីគេឯងញឹកញាប់ ។ វាក៏បង្ហាញមនុស្សឯទៀតផងដែរ ថាតើពួកគេអាចជួយកូនអ្នកដោយរបៀបណា ។




នៅពេលកូនធំបន្តិច ចូរឱ្យកូនដឹងថា ការនិយាយត្រាប់តាមសំដីគេឯង គឺមិនបញ្ជូនសារត្រឹមត្រូវឡើយ ។

## ➤ វិធីជួយកូនរៀនប្រើសព្វនាម

សព្វនាមមានដូចជាពាក្យ "គេ" "គាត់" "នាង" "អ្នក" ឬ "វា" ។ ពាក្យទាំងនេះអាចប្រើសំដៅទៅមនុស្ស ឬ វត្ថុជាច្រើនខុសៗគ្នា ។ កុមារគ្រប់រូបមានការលំបាកខ្លះៗក្នុងការរៀនប្រើពាក្យទាំងនេះឱ្យបានត្រឹមត្រូវ ។ ប៉ុន្តែកុមារដែលមិនអាចមើលឃើញច្បាស់មានការពិបាកកាន់តែច្រើន ពីព្រោះពួកគេមិនអាចមើលឃើញថាតើអ្នកណា ឬ អ្វីទៅដែលមនុស្សម្នាបាននិយាយសំដៅនោះ ឬ បុគ្គលដែលកំពុងនិយាយនោះជាបុរស ឬ ស្ត្រី ។ ជារឿយៗវាទាមទារពេលពីមួយ ឬ ពីរឆ្នាំសំរាប់ឱ្យកុមារដែលមិនអាចមើលឃើញច្បាស់ចេះប្រើសព្វនាមបានត្រឹមត្រូវ ។

ចូរប្រើសព្វនាមនៅពេលនិយាយជាមួយកូនអ្នក ទោះបីជាគេប្រើវាមិនត្រឹមត្រូវក៏ដោយ ។ តែត្រូវធ្វើឱ្យប្រាកដថាកូនដឹងថាអ្នកកំពុងនិយាយទៅរកគេ ។ អ្នកអាចនិយាយឈ្មោះកូនជាមុន ឬ ប៉ះកូនថ្នមៗដើម្បីទាក់ទាញការយកចិត្តទុកដាក់ពីកូន ។




ចូរលេងល្បែងដែលនិយាយអំពីចំណែកនៃរាងកាយ ។ នៅពេលកូនអ្នកចេះដឹងអំពីចំណែកនៃរាងកាយរបស់គេ ជួយគេឱ្យចេះស្វែងរកចំណែកដូចគ្នានោះលើរាងកាយមនុស្សដទៃ ។









បើសិនជាកូនអ្នកហាក់ដូចជាភាន់ច្រឡំ ចូរបង្ហាញកូនថាតើនរណាមួយដែលអ្នកកំពុងនិយាយសំដៅ ដោយការនាំឱ្យកូនចង្អុលទៅបុគ្គលដែលសព្វនាមសំដៅទៅរក ។




ចូរលេងល្បែងកំសាន្តដែលលើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរវេនគ្នា។ ចូរសង្កត់ធ្ងន់ទៅលើសព្វនាម នៅអំឡុងពេលអ្នកលេងកំសាន្ត។ បើកូនរបស់អ្នកកំពុងប្រើសព្វនាមមិនត្រឹមត្រូវដោយសារតែគេនិយាយត្រាប់តាមពាក្យសំដីមនុស្សដទៃ ចូរព្យាយាមប្រើប្រាស់យោបល់ដែលបានផ្តល់ឱ្យនៅផ្នែកខាងដើម ។

## ➤ វិធីជួយកូនបែរឱ្យចំបុគ្គលដែលកំពុងនិយាយ

កុមារពិការភ្នែកមិនដឹងថាគេត្រូវបែរឱ្យចំបុគ្គលដែលកំពុងនិយាយជាមួយគេនោះទេ ដោយសារគេមើលមិនឃើញមនុស្សដទៃកំពុងនិយាយ ។ ចូរលើកទឹកចិត្តឱ្យកុមារបែរទៅរកមនុស្សដទៃ ពេលគេកំពុងនិយាយទៅរកមនុស្សទាំងនោះ ។




**មុនដំបូង អ្នកអាចបង្វិលក្បាលកូនថ្នមៗ ឱ្យបែរមករកអ្នក នៅពេលអ្នកនិយាយ**




**នៅពេលកូនធំបន្តិច បង្រៀនកូនបែរឱ្យចំអ្នកនៅពេលអ្នកនិយាយ។**

### ➤ វិធីជួយកូនឱ្យសួរសំណួរកាន់តែតិច

កុមារស្ទើរតែទាំងអស់ចំណាយពេលវែងក្នុងការសួរសំណួរច្រើនទាល់តែយើងធុញ ។ តែជារឿយៗ កុមារពិការភ្នែកសួរសំណួរដែលចំណាយពេលកាន់តែយូរ ។ នេះប្រហែលដោយសារតែ :-

- ពួកគេមិនអាចមើលឃើញអ្វីៗដែលកើតឡើងជុំវិញខ្លួន ។
- ពួកគេមិនចេះពាក្យគ្រប់គ្រាន់ដើម្បីបន្តការនិយាយសន្ទនា ។
- ពួកគេចង់បានទំនាក់ទំនងជាមួយបុគ្គលដទៃ ។
- ជារឿយៗ ពួកគេត្រូវបានមនុស្សធំសួរសំណួរ ។

បើកូនអ្នកសួរសំណួរច្រើនពេកដែលធ្វើឱ្យអ្នកពិបាកឆ្លើយគ្រប់សំណួរទាំងអស់នោះ ឬក៏សំណួរទាំងនោះហាក់ដូចជារាំងស្ទះគេពីការរៀនសូត្រវិធីផ្សេងទៀតនៃការនិយាយស្តី កូនពិតជាត្រូវការជំនួយពីអ្នក ។

ចូរសង្កេតរកមើលអារម្មណ៍ដែលប្រហែលជាបង្កប់ពីក្រោយសំណួររបស់ក្មេង ។




ចូរនិយាយពីបទពិសោធន៍ថ្មីៗមុនពេលកូនចេះវា ។ វិធីនេះកូនមិនត្រូវការសួរសំណួរដើម្បីរកឱ្យឃើញពីអ្វីៗដែលបានប្រព្រឹត្តទៅ ។




ចូរស្តាប់ពីរបៀបដែលអ្នកបាននិយាយទៅរកកូន ។ តើអ្នកសួរសំណួរកូនច្រើនពេកទេ? បើដូច្នេះមែន ព្យាយាមបង្វែរសំណួរខ្លះរបស់អ្នកទៅជាការនិយាយបញ្ជាក់វិញ ។ ឧទាហរណ៍ ជំនួសឱ្យការសួរ "កូនចង់ទៅគេងឬទេ?" ចូរនិយាយថា :-

